# ការលួចស្នាដៃនិពន្ធ

## Plagiarism

ដោយ៖ **លោកស្រីបណ្ឌិត ព្រំ ទេវី**

*អនុប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

*រាជបណ្ឌិត្យសភាកម្ពុជា*

Email: promtevy@rac.gov.kh

## សេចក្តីផ្តើម

និស្សិតនិងអ្នកស្រាវជ្រាវភាគច្រើនតែងត្រូវការទិន្នន័យពីឯកសារដែលមានស្រាប់ដើម្បីឱ្យដឹងថាការស្រាវជ្រាវមុនៗបានធ្វើដល់ណាហើយមុននឹងចាប់ផ្តើមប្រមូលទិន្នន័យបឋមៗ ក្នុងការសរសេរកិច្ចការគរុកោសល្យមួយ សេចក្តីស្មោះត្រង់ជាការចាំបាច់បំផុតៗ ជាក់ស្តែងគ្រឹះស្ថានបណ្តុះបណ្តាលនានា តែងតម្រូវឱ្យនិស្សិតធ្វើការអះអាងជាសំណេរភ្ជាប់ជាមួយ កិច្ចការរបស់ខ្លួនថា ពិតជាស្នាដៃរបស់ខ្លួនពិតប្រាកដ ហើយពុំបានលួចចម្លងពីអ្នកដទៃឡើយៗ យោងតាមវចនានុក្រមអនឡាញ Cambridge បានកំណត់ថា[1] ៖

ការលួចស្នាដៃនិពន្ធគឺជាការប្រើប្រាស់គំនិតឬអត្ថបទរបស់អ្នកដទៃ យកមកធ្វើជារបស់ខ្លួនៗ អត្ថបទនៅទីនេះសំដៅដល់ទាំងអត្ថបទបោះពុម្ពផ្សាយ ទាំងមិនទាន់បោះពុម្ពផ្សាយ សំណៅសរសេរដៃ ទម្រង់អេឡិចត្រូនិច ឬផ្នែកណាមួយដែលបានមកពីបញ្ញាសិប្បនិម្មិតរួមទាំង អត្ថបទផ្ទាល់ខ្លួនផងដែរៗ

ហេតុអ្វីបានជាអ្នកស្រាវជ្រាវនិងនិស្សិតត្រូវចៀសវាងការលួចស្នាដៃនិពន្ធ? ការសរសេរកិច្ចការឧត្តមសិក្សាក៏ដូចជាកិច្ចការស្រាវជ្រាវផ្សេងទៀតដែរតែងមានក្បួនច្បាប់ពិតប្រាកដ ៗ ការបញ្ជាក់ភាពស្មោះត្រង់នេះមានន័យថា និស្សិតនិងអ្នកស្រាវជ្រាវលើកតម្កើងស្នាដៃរបស់ខ្លួនហើយក៏ជាការដឹងគុណដល់ម្ចាស់ស្នាដៃដើមដែរៗ

## ១- ទម្រង់ផ្សេងៗនៃការលួចស្នាដៃនិពន្ធ

ការលួចស្នាដៃនិពន្ធមានច្រើនបែបយ៉ាងណាស់ៗ ខាងក្រោមនេះជាចំណុចមួយចំនួនដែលរាប់បញ្ចូលថាជាការលួចស្នាដៃនិពន្ធ៖

### ១. ១- ការលួចចម្លងដោយចេតនា

ការលួចចម្លងប្រភេទនេះកើតឡើងញឹកញាប់ជាងគេ គឺជាសកម្មភាព ចម្លងយកកិច្ចការអ្នកដទៃ

[1] https://dictionary.cambridge.org/dictionary/english/plagiarism. Retrieved on 06-04-2024

ទាំងស្រុងឬផ្នែកណាមួយមកធ្វើជារបស់ផ្ទាល់ខ្លួន ហើយនិស្សិតក៏ដឹងដែរថាខ្លួនមានភាពមិនស្មោះត្រង់បែបនេះអាចមានផលប៉ះពាល់ដល់អាជីពរបស់និស្សិតនាពេលអនាគត។

អតីតរដ្ឋមន្ត្រីការពារជាតិអាល្លឺម៉ង់ឈ្មោះ Karl-Theodor Freiherr zu Guttenberg បាន បញ្ចប់ការសិក្សាថ្នាក់បណ្ឌិតនៅឆ្នាំ២០០៧។ ខែកុម្ភៈ ឆ្នាំ ២០១១គេបានរកឃើញថា គាត់បានលួចស្នាដៃនិពន្ធរបស់គេចំនួន១២១៨ករណីមក ពី ១៣៥ ប្រភពផ្សេងៗគ្នា ត្រូវជា ៣៧១ ទំព័រនៃ ៣៩៣ ទំព័រ(៩៤,៤%) និង១០ ៤២១បន្ទាត់ (៦៣,៨%)នៃនិក្ខេបបទរបស់គាត់សរុប[2]។ ក្រៅពីការដកហូតសញ្ញាបត្រថ្នាក់បណ្ឌិត ខែមីនាក្នុងឆ្នាំដដែល មុខតំណែងក៏ត្រូវបានបញ្ចប់ដែរ[3]។

## ១. ២- ការលួចចម្លងពីអ៊ីនធឺណិត

តាមរយៈ search engine ដូចជា google, Microsoft edge, Chrom នាពេលបច្ចុប្បន្ននេះ អ្នកស្រាវជ្រាវនិងនិស្សិតអាចទាញយកទិន្នន័យយ៉ាងសំបូរបែប។ ការប្រើប្រាស់ទិន្នន័យទាំងនោះ បើមិនមានបញ្ជាក់ប្រភពនិងកាលបរិច្ឆេទនៃការដកស្រង់ទេ ចាត់ទុកថាជាការលួចស្នាដៃនិពន្ធ។

ឧទាហរណ៍ : អត្ថបទមានចំណងជើងថា SMEs in Asia and the Pacific ដែលមានក្នុងអ៊ីនធឺណិត ពុំមានភ្ជាប់ឈ្មោះអ្នកនិពន្ធអ្វីទាំងអស់។ ដូច្នេះដើម្បីបង្ហាញប្រភពត្រូវប្រើគេហទំព័រ និងកាលបរិច្ឆេទនៃការដកស្រង់ភ្ជាប់ជាមួយផងដូចនេះ : https://www.unescap.org/sites/default/files/7 - SMEs in Asia and the Pacific.pdf. Retrieved on 06-04-2024។

## ១. ៣- ឃ្លាប្រយោគអ្នកដទៃ

ការយកឃ្លាប្រយោគរបស់អ្នកដទៃមកប្រើ ដោយគ្រាន់តែប្តូរ២ទៅ៣ពាក្យឬប្តូរលំដាប់នៃឃ្លាប្រយោគនោះ ចាត់ទុកថាជាការលួចស្នាដៃនិពន្ធ។ ត្រង់ចំណុចនេះ បើសិនជាអ្នកស្រាវជ្រាវឬនិស្សិតដាក់បង្ហាញត្រឹមប្រភព នោះមិនគ្រប់គ្រាន់ទេ ប្រសិនបើម្ចាស់ឃ្លាប្រយោគបានអានអត្ថបទយើងនោះគេនឹងដឹងថាជាឃ្លាប្រយោគរបស់គេ ជាពិសេសឃ្លាប្រយោគជាទ្រឹស្តី ក្នុងអត្ថបទមេរៀនរបស់គ្រូ អត្ថបទគោលនយោបាយជាតិឬអន្តរជាតិ ឬ លិខិតបទដ្ឋានគតិយុត្តណាមួយ។

ឧទាហរណ៍ : និស្សិត ក សរសេរនៅក្នុងអត្ថបទស្រាវជ្រាវមួយថា : សហគ្រាសទាំងឡាយនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ គួររួសរាន់រៀបចំចុះបញ្ជីដើម្បីប្រែក្លាយជាសហគ្រាសក្នុងប្រព័ន្ធ។ នេះជាលួចស្នាដៃនិពន្ធ។ អ្វីដែលត្រឹមត្រូវនោះគួរសរសេរថា៖

រាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៧នេះបានជម្រុញឱ្យសហគ្រាសទាំងឡាយនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ គួររួសរាន់រៀបចំចុះបញ្ជីដើម្បីប្រែក្លាយជាសហគ្រាសក្នុងប្រព័ន្ធ ដូចបានបញ្ជាក់

[2] GuttenPlag Wiki/English | GuttenPlag Wiki | Fandom. Retrieved on 06-04-2024

[3] https://en.wikipedia.org/wiki/Guttenberg_plagiarism_ scandal. Retrieved on 06-04-2024

ក្នុងយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨។

## ១. ៤- ការលួចស្នាដៃរួម

ក្នុងកំលុងពេលនៃការសិក្សា និស្សិតអាចទទួលបានការងារស្រាវជ្រាវជាក្រុមៗ អត្ថបទស្រាវជ្រាវនេះគឺជាកម្មសិទ្ធរួមរបស់សមាជិកក្រុម បើមានសមាជិកមួយ យកអត្ថបទនោះទៅប្រើធ្វើជាកម្មសិទ្ធផ្ទាល់ខ្លួនដោយមិនបង្ហាញឈ្មោះសមាជិកផ្សេងទៀត ចាត់ទុកថាជាការលួចស្នាដៃរួមៗ ឧទាហរណ៍ : អត្ថបទស្រាវជ្រាវមានចំណងជើងថាគម្រោងស្តីពីការកែលម្អបណ្ណាល័យនិងបំពាក់សៀវភៅអំណានកុមារនៅសាលាបឋមសិក្សារស្មីសាមគ្គីនៅស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ជាស្នាដៃស្រាវជ្រាវរបស់ ៖

១) លីឈាង សីហា ២) រិទ្ធ លក្ខិ្ម

៣) ណែម សុកគ្គិ ៤) សាន ច័ន្ទនីរ័ត្ន

និង ៥) សោម វណ្ណារ៉ាក់ដាលី ។

ឧបមាថា នរណាម្នាក់ក្នុងចំណោមអ្នកទាំង៥ យកខ្លឹមសារនៃកិច្ចការស្រាវជ្រាវទៅប្រើក្នុងកិច្ចការស្រាវជ្រាវណាមួយទៀត ត្រូវដាក់ឈ្មោះអ្នកនិពន្ធឱ្យបានគ្រប់គ្នា មិនមែនតែម្នាក់ឯងទេៗ

## ១. ៥- ការលួចចម្លងដោយស្វ័យប្រវត្តិ

មុននឹងឈានដល់ដំណាក់កាលសរសេរកិច្ចការគរុកោសល្យ និស្សិតភាគច្រើនអាចធ្លាប់បានសរសេរកិច្ចការអ្វីមួយផ្ទាល់ខ្លួនៗ នៅពេលសរសេរ សារណាឬនិក្ខេបបទ ក៏យកកិច្ចការនោះអាចជាផ្នែកខ្លះមកប្រើហើយពុំបានបញ្ជាក់ប្រភពទេព្រោះអាងថាជាកម្មសិទ្ធរបស់ខ្លួន ចាត់ទុកថាជាការលួចចម្លងដោយស្វ័យប្រវត្តិៗ

ឧទាហរណ៍ : ឆ្នាំ២០០៨ ឈ្មោះ ក បានសរសេរសៀវភៅមួយមានចំណងជើងថាការរៀបចំគម្រោងស្រាវជ្រាវដោយខ្លួនឯង លុះដល់ឆ្នាំ២០១៩អ្នកនិពន្ធដដែលសរសេរអត្ថបទថ្មីមួយទៀត មានចំណងជើងថាវិធីសាស្ត្រស្រាវជ្រាវៗ បើសិនជាមានការប្រើប្រាស់ខ្លឹមសារ ឬ ទិន្នន័យក្នុងរូបភាពណាក៏ដោយចេញពីសៀវភៅដែលបានផ្សព្វផ្សាយហើយ ត្រូវបញ្ជាក់ប្រភពក្នុងកំណត់សម្គាល់ផ្នែកខាងក្រោមនៃទំព័រនិង/ឬក្នុងគន្ថនិទ្ទេសៗ

## ១. ៦- ដាក់ឈ្មោះអ្នកនិពន្ធមិនគ្រប់គ្រាន់

ករណីខ្លះឯកសារដែលយកមកប្រើមានអ្នកនិពន្ធលើសពី១នាក់ៗ ដោយខ្វះខាតពេលវេលា ឬមិនបានយកចិត្តទុកដាក់ អ្នកស្រាវជ្រាវឬនិស្សិតបានកត់ត្រាតែឈ្មោះអ្នកនិពន្ធទី១ ហើយអ្នកផ្សេងទៀតមិនបានកត់ត្រាៗ

ឧទាហរណ៍ : សៀវភៅដែលមានចំណងជើងថា អាទិទេពក្រុងអង្គរ ជាស្នាដៃនិពន្ធរបស់ ថាច់ វ៉ាន់ផាត និង កែវ សូកុន បោះពុម្ពដោយរោងពុម្ពរាស្ត្រសច្ចៈ នៅក្រុងភ្នំពេញនាឆ្នាំ១៩៧៣ៗ នៅក្នុងកំណត់ចំណាំផ្នែកខាងក្រោមនៃទំព័រនិងគន្ថនិទ្ទេស ចាំបាច់ណាស់ត្រូវសរសេរឈ្មោះអ្នកនិពន្ធ២នាក់ មិនអាចបំភ្លេចមួយណាបានឡើយក្នុងទម្រង់បែបនេះ៖

*ថាច់ វ៉ាន់ផាត និង កែវ សូគុន : អាទិទេពក្រុងអង្គរ ភ្នំពេញ រោងពុម្ព រាស្ត្រសច្ចៈ ឆ្នាំ១៩៧៣*

## ១. ៧- ឈ្មោះនិពន្ធមិនច្បាស់លាស់

*អត្ថបទស្រាវជ្រាវមួយចំនួនធំមានការដកស្រង់ឃ្លាប្រយោគ ហើយមានដាក់ឈ្មោះម្ចាស់អត្ថបទដើម។ ឈ្មោះម្ចាស់អត្ថបទដើម ចំណងជើង អត្ថបទ ទីកន្លែងនិងកាលបរិច្ឆេទនៃការបោះពុម្ពផ្សាយអត្ថបទនោះ អាចមាននៅក្នុងអត្ថបទឬនៅក្នុងកំណត់ចំណាំផ្នែកខាងក្រោមនៃទំព័រ។ បើអ្នកស្រាវជ្រាវនិងនិស្សិតចង់ដកស្រង់ឃ្លាប្រយោគដដែលនោះ ត្រូវដាក់ឈ្មោះម្ចាស់អត្ថបទដើម មិនមែនឈ្មោះអ្នកនិពន្ធអត្ថបទដែលកំពុងអានទេ។ បើពុំមានលទ្ធភាពរកឃើញអត្ថបទទី១ទេ គួរបន្ថែមពាក្យថា នៅក្នុង អត្ថបទទី២ ដែលកំពុងអាន។*

*ឧទាហរណ៍ : ក្នុងអត្ថបទមានចំណងជើងថា គំនិតផ្តួចផ្តើមផ្លូវនិងខ្សែក្រវាត់ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅកម្ពុជា ចេញផ្សាយពីខែឧសភា ឆ្នាំ២០១៩ ឈ្មោះ ក បានលើកឡើងថាគោលការណ៍គន្លឹះសម្រាប់គំនិតផ្តួចផ្តើមផ្លូវនិងខ្សែ ក្រវាត់ចំនួន៥គឺ : ១) ជាវិថីដើម្បីសន្តិភាព ២) ជាវិថីដើម្បីភាពរីចម្រើន ៣) ជាវិថីសម្រាប់ការបើកចំហរ ៤) ជាវិថីសម្រាប់នវានុវត្តន៍ និង៥) ជាវិថីផ្សាភ្ជាប់អរិយធម៌។ ដាក់ស្តែងចំណុចនេះ មិនមែនជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ទេ តែបានស្រង់ពី* Xi Jinping: Speech at the Opening Ceremony of the Belt and Road Forum for Internatio-nal Cooperation, 14 May 2017។ *ក្នុងន័យនេះ បើសិនមានការយកគំនិតដដែលនេះទៅប្រើបន្ត ត្រូវដាក់ឈ្មោះម្ចាស់ដើមគឺ* Xi Jinping *ហើយមិនមែន ឈ្មោះ ក ទេ ក្នុងទម្រង់បែបនេះ៖*

Xi Jinping: Speech at the Opening Ceremony of the Belt and Road Forum for International Cooperation, 14 May 2017

*តែបើមិនមានលទ្ធភាពទទួលបានអត្ថបទដើមខាងលើនេះទេ ត្រូវសរសេរថា៖*

Xi Jinping: Speech at the Opening Ceremony of the Belt and Road Forum for International Cooperation, 14 May 2017 ***នៅ*** *ក្នុង: ក :គំនិតផ្តួចផ្តើមផ្លូវនិងខ្សែក្រវាត់ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅកម្ពុជា ភ្នំពេញ ឆ្នាំ២០១៩។*

## ១. ៨- មិនដាក់ឈ្មោះម្ចាស់ដើមអត្ថបទបកប្រែ

*អត្ថបទមួយចំនួនជាស្នាដៃបកប្រែ បើនិស្សិតនិងអ្នកស្រាវជ្រាវមិនបានសរសេរឈ្មោះអ្នកនិពន្ធទេ តែសរសេរឈ្មោះអ្នកបកប្រែ នោះជាការលួចស្នាដៃនិពន្ធ។*

*ឧទាហរណ៍ : សៀវភៅមានចំណងជើងថា ហ៊ុន សែន បុរសខ្លាំងរបស់កម្ពុជា ជាស្នាដៃបកប្រែដោយលោកកែ សឿងនិងជួន នឿន ហើយម្ចាស់អត្ថបទដើមគឺ* Harh C. Mehta & Julie B. Mehta *ដែលមានចំណងជើងដើមថា* ***Hun Sen.***

*Strongman of Cambodia*។ កាលណាសរសេរត្រឹមតែ៖

កែ សឿង និង ជួន នឿន : ហ៊ុន សែន បុរសខ្លាំងរបស់កម្ពុជា រោងពុម្ពបាយ័ន ក្រុងតាខ្មៅ ឆ្នាំ ២០០០

ជាការលួចស្នាដៃនិពន្ធ បើសរសេរដូចនេះ៖

-Harh C. Mehta & Julie B. Mehta : ហ៊ុន សែន បុរសខ្លាំងរបស់កម្ពុជា  បកប្រែពីភាសាអង់គ្លេស ដោយ កែ សឿង និងជួន នឿន ក្រុងតាខ្មៅ រោងពុម្ព បាយ័ន ឆ្នាំ២០០០ (ចំណងជើងដើម : Hun Sen. Strongman of Cambodia. Graham Brash, Singapore,1999.) ជាការត្រឹមត្រូវ។

**១. ៩- មិនបានបញ្ជាក់ឈ្មោះអ្នកជួយ**

ក្នុងការសរសេរកិច្ចការគរុកោសល្យមួយ និស្សិតមានគ្រូណែនាំនិងអាចមានអ្នកជួយពិនិត្យអក្ខរាវិរុទ្ធ។ ទាំងគ្រូណែនាំ ទាំងអ្នកជួយពិនិត្យអក្ខរាវិរុទ្ធ និស្សិតតែងរំលឹកឈ្មោះនៅក្នុងសេចក្តីថ្លែងអំណរគុណ។ ក៏ប៉ុន្តែនៅក្នុងគម្រោងស្រាវជ្រាវធំៗ ដូចជាការសរសេរនិក្ខេបបទថ្នាក់បណ្ឌិតជាដើម បេក្ខជនបណ្ឌិតអាចទទួលបានគំនិតយោបល់ពីមិត្តភក្តិ បុគ្គលិកបណ្ណាល័យ អ្នកបច្ចេកទេសមន្ទីរពិសោធន៍ សាស្ត្រាចារ្យ អាជ្ញាធរមូលដ្ឋាន និងអ្នកផ្សេងទៀត ហើយនិងខ្លឹមសារនៃមតិយោបល់នោះបានក្លាយជាខ្លឹមសារនៃកិច្ចការស្រាវជ្រាវដូច្នេះ ឈ្មោះរបស់អ្នកទាំងនោះគួរបញ្ជាក់ក្នុងនិក្ខេបបទផង។

## ២- វិធីសាស្ត្រចៀសវាងការលួចស្នាដៃនិពន្ធ

ការស្រាវជ្រាវឯកសារដែលមានស្រាប់ដើម្បីឱ្យយល់ដឹងពីខ្លឹមសារនៃការស្រាវជ្រាវពីមុនៗ ការដកស្រង់គំនិត...ជាផ្នែកមួយដ៏សំខាន់នៃការសិក្សាស្រាវជ្រាវ។ ដូចបានបង្ហាញខាងលើ អ្នកស្រាវជ្រាវ ឬនិស្សិត ងាយក្លាយ ទៅអ្នកលួចស្នាដៃនិពន្ធ។ ខាងក្រោមនេះ ជាវិធីសាស្ត្រ មួយចំនួន ដើម្បីចៀសវាងការលួចស្នាដៃនិពន្ធ៖

**២. ១- កុំចម្លង**

ការចម្លងឃ្លាប្រយោគឬកថាខណ្ឌណាមួយមកដាក់ក្នុងអត្ថបទរបស់យើងជាការមិនល្អឡើយ ទោះអត្ថបទដើមនោះជារបស់យើងផ្ទាល់ក៏ដោយ។ និស្សិតនិងអ្នកស្រាវជ្រាវអាចដកស្រង់ឃ្លាល្បះខ្លីបាន ហើយដាក់ក្នុងអព្ភន្តរសញ្ញាដោយមានបញ្ជាក់ប្រភពឱ្យបានច្បាស់លាស់។ សម្រង់ឃ្លាប្រយោគដោយមានការបង្ហាញបែបនេះ មិនមែនបានសេចក្តីថាជាការលួចស្នាដៃនិពន្ធដោយឥតលាក់លៀមនោះទេ តែជារឿងកើតមានជាធម្មតាក្នុងការសិក្សាស្រាវជ្រាវ។

**២. ២- ប្រើពាក្យផ្ទាល់ខ្លួន**

ការប្រើពាក្យផ្ទាល់ខ្លួនគឺជាការប្រសើរណាស់ ដើម្បីចៀសវាងការប្រើរបស់អ្នកដទៃ។ បានន័យថា និស្សិតនិងអ្នកស្រាវជ្រាវគួរចៀសវាងការសរសេរតាមឬចម្លងពីគេឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ ការសរសេរតាមឬចម្លងដោយបន្ថែមពាក្យដូចជា **របស់ នៅក្នុង**

ជាការអនុគ្រោះ នៅក្នុងអត្ថបទស្រាវជ្រាវក្នុង កម្រិតតិចតួចប៉ុណ្ណោះ ដោយមានបញ្ជាក់ប្រភព ក្នុងកំណត់ចំណាំផ្នែកខាងក្រោមនៃទំព័រឬ/និង នៅក្នុងគន្ថនិទ្ទេស ក៏ប៉ុន្តែវិធីសាស្ត្រដែលល្អ បំផុតដូចបានបញ្ជាក់ខាងលើអីចឹងគឺ ប្រើពាក្យ ផ្ទាល់ខ្លួន។

**២. ៣- ចម្លងដើម្បីឱ្យច្បាស់សេចក្តី**

ក្នុងករណីខ្លះ បើប្រើពាក្យផ្ទាល់ខ្លួន ហាក់ ដូចជាមិនអស់សេចក្តី និងសម្រេចចិត្តធ្វើការដក ស្រង់ឃ្លាប្រយោគ។ ការដកស្រង់នេះ មិនមែន ស្រង់របស់គេ យកមកដាក់ក្នុងអត្ថបទយើង ទាល់តែរកពាក្យផ្ទាល់ខ្លួន មិនឃើញនោះទេ ពាក្យឬឃ្លាប្រយោគមិនចាំបាច់ខ្លះ មិនគួរយក មកសរសេរឡើងវិញដោយដាក់ក្នុងអព្ភន្តរ សញ្ញាទេ តែការពិភាក្សាអំពីគំនិតឬទស្សនៈ នោះ គឺជាការប្រសើរបំផុត ហើយមានការ បញ្ជាក់ប្រភពក្នុងកំណត់ចំណាំផ្នែកខាង ក្រោមនៃទំព័រឬ/និងនៅក្នុងគន្ថនិទ្ទេស។

**២. ៤- កុំប្រើឡើងវិញនូវអត្ថបទផ្ទាល់ខ្លួន**

អ្នកស្រាវជ្រាវនិងនិស្សិតមិនត្រូវប្រើឡើង វិញនូវអត្ថបទដែលខ្លួនបាន ផ្សព្វផ្សាយម្តងរួច ហើយដោយពុំមានបញ្ជាក់ប្រភពនោះទេ ក្នុង នោះ រាប់បញ្ចូលទាំងរូបភាព តារាងផងដែរ។ បើ សិនជាបានយកមកប្រើ នោះមានឈ្មោះថា លួច ស្នាដៃនិពន្ធខ្លួនឯង។

**២. ៥- សុំការអនុញ្ញាត**

ការប្រើប្រាស់តារាង រូបភាព ឬ ទិន្នន័យ ប្រភេទណាក៏ដោយដែលមិនទាន់បាន ផ្សព្វផ្សាយ ពីមុនមក ឬមួយទិន្នន័យ នោះ បានរៀបចំដោយអ្នកណាម្នាក់ដែលមិនមែន សហនិពន្ធ ត្រូវតែសុំការអនុញ្ញាតិសិន។

**សេចក្តីសន្និដ្ឋាន**

ការលួចស្នាដៃនិពន្ធជាអំពើមិនស្មោះត្រង់និង អយុត្តិធម៌។ កាលណាស្នាដៃនិពន្ធមួយត្រូវបានគេ លួច ម្ចាស់ស្នាដៃនោះជាជនរងគ្រោះ រីអ្នកលួច ស្នាដៃរបស់គេជាអ្នកសាងភាពអយុត្តិធម៌។ ប្រការនេះធ្វើឱ្យអ្នកលួចគេលែងចង់រៀនសិក្សា ស្រាវជ្រាវអ្វីទាំងអស់។ ការលួចស្នាដៃនិពន្ធគឺជា ការបញ្ឈប់នូវការរីកចម្រើននៃចំណេះដឹង និងគំនិត។

## គន្ថនិទ្ទេស


- Vinayak Bairagi and Mousami V. Munoy(ed.): Research Methodology, A Practical and Scientific Approach
- https://dictionary.cambridge.org/dictionary/ english/plagiarism
- https://en.wikipedia.org/wiki/Guttenberg plagiarism scandal

- GuttenPlag Wiki/English | GuttenPlag Wiki | Fandom
- https://libguides.usc.edu/writingguide/literaturereview
- https://www.scanmyessay.com/plagiarism/types-of-plagiarism.php
- https://www.ox.ac.uk/students/academic/guidance/skills/plagiarism
- How to Avoid Plagiarism: 5 Easy Methods | Grammarly